**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ០១៣ ........ បទ.ប្រក...

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៧

# ប្រកាស

## ស្តីអំពីតាំងលេខ Telephone Numbering and Signaling Point Code

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញ អនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍។
- បានឃើញ សេចក្តីសម្រេចលេខ ១៥៨សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រម គ្រប់គ្រងតម្លៃ។
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី។
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍។
- បានឃើញ អនុក្រឹត្យលេខ ៦៦អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍។
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា។
- បានឃើញ សេចក្តីសម្រេចលេខ ៨៦អនក្រ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និង បំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃ ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍។

- បានឃើញកំណត់ហេតុអង្គប្រជុំនៃប្រតិបត្តករទាំងអស់ចំនួនពីរលើកនៅទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ កាលពីថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០២ និង ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការតម្រូវអោយក្រុមហ៊ុននិមួយៗបង់ថ្លៃប្រើប្រាស់ Telephone Numbering និង Signaling Point Code ដែលខ្លួនប្រើចាប់ពីពាក់កណ្តាលឆ្នាំ ២០០២ តទៅ ។

<u>សម្រេច</u>

ប្រការ១: កំណត់ថ្លៃប្រើប្រាស់ Telephone Numbering និង Signaling Point Code ដូចមានឧបសម្ព័ន្ធទី១ ភ្ជាប់នឹងសេចក្តីប្រកាសនេះ។

ប្រការ២: រាល់បញ្ញត្តិនៃប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ៣: ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួងប.ទ ត្រូវទទួលបន្ទុក អនុវត្តតាមតួនាទី ភារកិច្ចនៃប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៤: ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

សូ ខុន

<u>ចម្លងជូន</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## ថ្លៃប្រើប្រាស់ Telephone Numbering និង Signaling Point Code

| | | |
|---|---|---|
| ១- | លេខទូរស័ព្ទ (Telephone Numbering) | តម្លៃ(ដុល្លារអាមេរិក)/១ឆ្នាំ |
| | ក/ ទូរស័ព្ទអចល័ត ( Fixed Phone ) | |
| | 0AB NXXXXX | ៧០០ |
| | AB លេខកូដតំបន់ (ឧទាហរណ៏ ២៣-សំរាប់ក្រុងភ្នំពេញ.....។ល។)<br>N ជាលេខមួយប្រាកដ(លើកលែងលេខ ០,១)សំរាប់សំគាល់ស្ថានីយ៍ ទូរស័ព្ទ ឬ Network Operator នីមួយៗ ។ | |
| | ខ/ ទូរស័ព្ទចល័ត ( Mobile Phone ) | |
| | 01N XXXXXX ឬ<br>09N XXXXXX | ១៥០០ |
| | N ជាចំនួនលេខអាចយកចាប់ពី ០ រហូតដល់ ៩ | |
| | គ/ សេវាបំរើទូរស័ព្ទដោយមិនគិតថ្លៃ គឺលេខ ១៨០០(Free Phone service) និងសេវា ១៩០០ (Charge Call service) | |
| | លេខ 1800 NXX XXX (Free Phone Service) | ១០០០ |
| | លេខ 1900 NXX XXX (Charge Call Number) | ១០០០ |
| | ដែល N = 1,2,3,...,9 . | |
| ២- | Signaling Point Code ( SPC ) | |
| | ក/ National Signaling Point Code (SPC) | ២៥០ |
| | ខ/ International Signaling Point Code (ISPC) | ២០០០ |